

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ. បព ១៦៧ / ២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តម ម៉ាក ជូសេហ្វ ខានី
នាយករដ្ឋមន្ត្រីនៃប្រទេសកាណាដា មកកាន់ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦

តបតាមការអញ្ជើញដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម ម៉ាក ជូសេហ្វ ខានី** នាយករដ្ឋមន្ត្រីនៃប្រទេសកាណាដា បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ បន្ទាប់ពី **ឯកឧត្តម** បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅរាជធានីភ្នំពេញ។ ដំណើរទស្សនកិច្ចផ្លូវការនេះមានគោលបំណងធ្វើឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការដែលកំពុងរីកលូតលាស់រវាងប្រទេសទាំងពីរ។

នៅមុនពិធីស្វាគមន៍ផ្លូវការ **ឯកឧត្តមនាយករដ្ឋមន្ត្រី ម៉ាក ជូសេហ្វ ខានី** បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ»** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ទីបំផុត។

ឯកឧត្តមនាយករដ្ឋមន្ត្រី បានជួបពិភាក្សាទ្វេភាគីជាមួយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ប្រកបដោយផ្លែផ្កា។ កិច្ចពិភាក្សារវាងនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ មានលក្ខណៈត្រង់ទៅត្រង់មក និងប្រកបដោយស្មារតីស្ថាបនា ដោយគ្របដណ្តប់លើបញ្ហាជាច្រើន រួមមាន៖ ពាណិជ្ជកម្ម ការវិនិយោគ ការតភ្ជាប់ វិស័យទេសចរណ៍ ការបោសសម្អាតមីន វិស័យកសិកម្ម សន្តិសុខ និងការពារជាតិ។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈលើការវិវត្តនៃសភាពការណ៍ក្នុងតំបន់ និងអន្តរជាតិផងដែរ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការផ្នែកនយោបាយ នាយករដ្ឋមន្ត្រីទាំងពីរបានសង្កត់ធ្ងន់លើសារៈសំខាន់នៃទំនាក់ទំនងមិត្តភាពដែលកំពុងរីកចម្រើន និងបង្កើនកិច្ចសហប្រតិបត្តិការដែលផ្តល់ប្រយោជន៍ទៅវិញទៅមករវាងកម្ពុជា និងកាណាដា។ ភាគីទាំងពីរបានប្តេជ្ញាធ្វើការរួមគ្នាដើម្បីបុព្វហេតុនៃការអភិវឌ្ឍប្រកបដោយចីរភាព សន្តិភាព ស្ថិរភាព និងរុីលភាពរួម ព្រមទាំងបានគូសបញ្ជាក់នូវគុណតម្លៃនៃការផ្លាស់ប្តូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងជាទៀងទាត់នៅគ្រប់កម្រិត ដូចជាការរៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី២ រវាងក្រសួង

ការបរទេសនៃប្រទេសទាំងពីរនៅទីក្រុងភ្នំពេញ កាលពីខែកុម្ភៈកន្លងទៅ។ កម្ពុជាបានបញ្ជាក់សាជាថ្មីនូវបំណងក្នុងការបើកស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងអូតាវ៉ា ប្រទេសកាណាដាក្នុងអនាគតដ៏ខ្លីខាងមុខ ដើម្បីពង្រឹងការប្រាស្រ័យទាក់ទងឱ្យកាន់តែជិតស្និទ្ធរវាងប្រជាជាតិទាំងពីរ។

ចំពោះវិស័យពាណិជ្ជកម្ម និងវិនិយោគ ថ្នាក់ដឹកនាំទាំងពីរបានស្វាគមន៍ចំពោះភាពរីកចម្រើនជាវិជ្ជមាននៃទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគី និងបានសន្យាខិតខំរួមគ្នាពង្រីកទំហំពាណិជ្ជកម្ម ធ្វើពិពិធកម្មវិស័យនានានៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ព្រមទាំងបង្កើតកាលានុវត្តភាពថ្មីៗសម្រាប់ធុរកិច្ច និងវិនិយោគិន តាមរយៈអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច ដែលទើបបានចុះហត្ថលេខាថ្មីៗនេះ។ ភាគីទាំងពីរក៏បានសង្កត់ធ្ងន់លើសារៈសំខាន់ នៃការផ្លាស់ប្តូរទស្សនកិច្ចជាទៀងទាត់របស់គណៈប្រតិភូធុរកិច្ចជាន់ខ្ពស់ ដើម្បីពង្រឹងទំនាក់ទំនងធុរកិច្ច ស្វែងរកកាលានុវត្តភាពដែលអាចធ្វើកិច្ចសហការបាន។

នាយករដ្ឋមន្ត្រីទាំងពីរបានរំលេចនូវសារៈសំខាន់នៃការពង្រីកការផ្លាស់ប្តូរទំនាក់ទំនងរវាងប្រជាជន និងប្រជាជន តាមរយៈកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ ទេសចរណ៍ និងវប្បធម៌។ ក្នុងន័យនេះ កម្ពុជាបានស្វាគមន៍ចំពោះការកើនឡើងនៃចំនួនភ្ញៀវទេសចរជនជាតិកាណាដា និងបានកត់សម្គាល់នូវសក្តានុពលដ៏ខ្លាំងក្លាក្នុងការជំរុញវិស័យទេសចរណ៍ទៅវិញទៅមក។

ចំពោះសកម្មភាពបោសសម្អាតមីន កម្ពុជាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសកាណាដា ដែលបានផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់កិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីន និងការគាំទ្រសម្រាប់ជនរងគ្រោះដោយសារគ្រាប់មីន និងបានបញ្ជាក់ជាថ្មីនូវសារៈសំខាន់នៃការបន្តគាំទ្ររបស់ប្រទេសកាណាដាសម្រាប់ការសម្រេចបាននូវគោលដៅ «កម្ពុជាមួយគ្មានផលប៉ះពាល់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម»។

ចំពោះទំនាក់ទំនងអាស៊ាន-កាណាដា **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់កាណាដាចំពោះគោលការណ៍មជ្ឈភាពអាស៊ាន និងការចូលរួមយ៉ាងសកម្មក្នុងយន្តការដែលដឹកនាំដោយអាស៊ាន រួមមាន វេទិកាតំបន់អាស៊ាន ជាដើម។ លើសពីនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានស្វាគមន៍ចំពោះវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាន**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា** ដែលនឹងពន្លឿនការផ្លាស់ប្តូរទាក់ទងពាណិជ្ជកម្ម និងការវិនិយោគរវាងកាណាដា និងអាស៊ាន។

ចំពោះបញ្ហាក្នុងតំបន់ និងសកលលោក នាយករដ្ឋមន្ត្រីទាំងពីរបានប្តេជ្ញាចិត្តផ្តល់ការគាំទ្រ និងការសម្របសម្រួលគ្នាទៅវិញទៅមកនៅក្នុងវេទិកាតំបន់ និងអន្តរជាតិ ព្រមទាំងគូសបញ្ជាក់នូវសារៈសំខាន់ នៃការពង្រឹងកិច្ចសហប្រតិបត្តិការលើការដោះស្រាយបញ្ហាប្រឈមរួម ដែលមានជាអាទិ៍ សន្តិសុខសាយប័រ បញ្ញាសិប្បនិម្មិត សេវាកម្មហិរញ្ញវត្ថុ និងការប្រយុទ្ធប្រឆាំងនឹង

ឧក្រិដ្ឋកម្មឆ្លងដែន ដូចជា ការធបោកតាមប្រព័ន្ធបច្ចេកវិទ្យា ជាដើម។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជម្រាបជូន **ឯកឧត្តមនាយករដ្ឋមន្ត្រី** អំពីស្ថានការណ៍បច្ចុប្បន្ននៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងបានថ្លែងអំណរគុណចំពោះការគាំទ្ររបស់ប្រទេសកាណាដា ក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធី និងការផ្តល់ជំនួយមនុស្សធម៌ដល់គ្រួសារកៀសសឹកកម្ពុជានៅតាមតំបន់ព្រំដែនដែលមានជម្លោះ។

ឯកឧត្តមនាយករដ្ឋមន្ត្រី បានកោតសរសើរកម្ពុជា ចំពោះជោគជ័យនៃការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ និងព្រឹត្តិការណ៍ពាក់ព័ន្ធ នៅរាជធានីភ្នំពេញចាប់ពីថ្ងៃទី១៣ ដល់ ១៧ ខែវិច្ឆិកា ឆ្នាំ២០២៦។ ជាការឆ្លើយតប **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រ និងការចូលរួមយ៉ាងសកម្មរបស់ប្រទេសកាណាដាក្នុងព្រឹត្តិការណ៍អន្តរជាតិជាប្រវត្តិសាស្ត្រនេះ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអបអរសាទរប្រទេសកាណាដា ដែលនឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២១ ក្នុងឆ្នាំ២០២៨ ខាងមុខ។

បន្ទាប់ពីកិច្ចពិភាក្សាទ្វេភាគី **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានអញ្ជើញធ្វើជាសាក្សីនៃការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួន ២ រួមមាន៖

១. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ច រវាងកម្ពុជា និងកាណាដា

២. អនុស្សរណៈនៃការយោគយល់គ្នាស្តីពីការផ្លាស់ប្តូរព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ រវាងមជ្ឈមណ្ឌលវិភាគប្រតិបត្តិការនិងរបាយការណ៍ហិរញ្ញវត្ថុនៃប្រទេសកាណាដា និង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ថ្នាក់ដឹកនាំទាំងពីរ ក៏បានប្រកាសអំពីការចាប់ផ្តើមកិច្ចពិភាក្សាដំបូងលើកិច្ចព្រមព្រៀងស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការជំរុញ និងការការពារវិនិយោគបរទេស រវាងកម្ពុជា និងកាណាដា។

ឯកឧត្តមនាយករដ្ឋមន្ត្រី ម៉ាក ខានី បានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ព្រមទាំងប្រជាជនកម្ពុជា ដែលបានផ្តល់បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជូនគណៈប្រតិភូកាណាដា។ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានគោរពអញ្ជើញ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បំពេញទស្សនកិច្ចផ្លូវការនៅប្រទេសកាណាដា តាមពេលវេលាសមស្របសម្រាប់ភាគីទាំងពីរ ដែល **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានទទួលយកការអញ្ជើញនេះដោយសេចក្តីសោមនស្សរីករាយ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ២០២៦